雲南日報
YUNNAN DAILY PRESS GROUP
云南日报报业集团
No.209

# ប្រទេសចិន-ខេត្តយូនណាន

រស្មីកម្ពុជា ប្រចាំថ្ងៃ

khmerlight@163.com
yunnangateway.com
Follow Amazing Yunnan on Facebook

ឆ្នាំទី28លេខ8131 ថ្ងៃសុក្រ ទី17 ខែមករា ឆ្នាំ2020

## នៅឆ្នាំ២០១៩ប្រទេសចិនទទួលសមិទ្ធផលច្រើនគួរឱ្យកត់សម្គាល់ក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន




*នាង ស្យូង យូឡាន ជនជាតិទូឡុងខេត្តយូនណានពាក់ វ៉ែនតាព្រារលើកទី១ ដើម្បីគយគន់ ទេសភាពបឹងទានឈើនិងភ្នំស៊ីសានតាម បណ្តាញសេវា5G*

នៅឆ្នាំ២០១៩ ជីវភាពរស់នៅរបស់ប្រជាជនចិនបានផ្លាស់ប្តូរយ៉ាងច្រើន ។ ការធ្វើដំណើរកាន់តែមានភាពងាយស្រួលប្រព័ន្ធធានារ៉ាប់រងគ្របដណ្តប់លើវិស័យកាន់តែច្រើន សេវាកម្មបណ្តាញអ៊ីនធឺណិតមានល្បឿនកាន់តែលឿននិងមានតម្លៃកាន់តែទាប ។ ក្រសួងផ្សេងៗបានសម្រេចនូវគោលដៅអំពីការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនដែលលើកឡើងនៅដើមឆ្នាំ២០១៩ ហើយបានធ្វើឱ្យប្រជាជនចិនមានជីវភាពរស់នៅកាន់តែល្អប្រសើរ ។

ការធ្វើដំណើរកាន់តែមានភាពងាយស្រួល។ គិតមកដល់ពេលនេះប្រទេសចិនបានសាងសង់និងជួសជុលផ្លូវប្រវែង២៩ម៉ឺនគីឡូម៉ែត្រក្នុងតំបន់ជនបទដែលលើសពីគោលដៅដែលបានកំណត់ហើយបានសាងសង់ផ្លូវក្រាលស៊ីម៉ងត៍ឬកៅស៊ូនៅឃុំ និងភូមិខ្លះមុនពេលកំណត់ ។ ជាពិសេសប្រទេសចិនបានសម្រេចនូវការតភ្ជាប់ទីក្រុងចំនួន២៧៥ និងស្រុកចំនួន ៤៤៨ដោយប្រើសំបុត្រជិះឡានក្រុងតែមួយ ។

នៅឆ្នាំ២០១៩ ប្រទេសចិនបានដាក់ឱ្យប្រើប្រាស់នូវខ្សែរថភ្លើងល្បឿនលឿនជាង១០ខ្សែ ដែលមានប្រវែងសរុបជាង៥.០០០គីឡូម៉ែត្រ ។ ខ្សែរថភ្លើងល្បឿនលឿនទូទាំងប្រទេសចិនមានប្រវែងសរុបជាង៣,៥ម៉ឺនគីឡូម៉ែត្រ ជាប់លំដាប់លេខ១ លើពិភពលោក ។

សេវាកម្មបណ្តាញអ៊ីនធឺណិតមានល្បឿនកាន់តែលឿននិងមានតម្លៃកាន់តែថោក ។ នៅចុងឆ្នាំ២០១៩ រដ្ឋាភិបាលចិនបានប្រកាសនូវរបាយការណ៍ការងាររដ្ឋាភិបាលជាសាធារណៈ ។ តាមរបាយការណ៍នេះបានឱ្យដឹងថា ប្រទេសចិនបានសម្រេចនូវគោលដៅអំពីការបង្កើនល្បឿន និងបន្ថយតម្លៃនៃការប្រើបណ្តាញអ៊ីនធឺណិត ។ រដ្ឋាភិបាលចិនបានចាត់វិធានការពិសេសមួយចំនួនធំដូចជាបន្ថយចំណាយនៃការប្រើបណ្តាញអ៊ីនធឺណិតរបស់សហគ្រាសធុនតូចនិងមធ្យមផ្តល់សេវាកម្មបណ្តាញអ៊ីនធឺណិតដែលមានតម្លៃពិសេសសម្រាប់មនុស្សចាស់ និងប្រជាជនដែលមានចំណូលទាបផ្តល់ការអនុគ្រោះដល់គ្រួសារក្រីក្រនិងបន្ថយតម្លៃនៃការប្រើប្រាស់បណ្តាញអ៊ីនធឺណិតតាមទូរស័ព្ទរបស់ប្រជាជនចិនដីគោកនៅពេលធ្វើដំណើរទៅតំបន់ហុងកុងនិងម៉ាកាវជាដើម ។

នៅខែមិថុនាឆ្នាំ២០១៩ ក្រសួងឧស្សាហកម្មនិងព័ត៌មានវិទ្យាចិនបានផ្តល់អាជ្ញាប័ណ្ណសេវា៥G ដល់ក្រុមហ៊ុន CHINA TELECOM, CHINA MOBILE, CHINA UNICOM និងក្រុមហ៊ុនវិទ្យុនិងទូរទស្សន៍ចិន ។ នេះបានបង្ហាញឱ្យឃើញថាប្រទេសចិនបានឈានចូលក្នុងយុគសម័យសេវា៥G ជាផ្លូវការ ។ ក្នុងឆ្នាំថ្មីនេះ យុគសម័យសេវា៥G នឹងជំរុញការតភ្ជាប់គ្នានូវវត្ថុអ្វីៗទាំងអស់ហើយនឹងនាំមកនូវការផ្លាស់ប្តូរច្រើនគួរឱ្យកត់សម្គាល់ដល់ជីវភាពរស់នៅរបស់ប្រជាជន ព្រមទាំងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ។

ប្រព័ន្ធធានារ៉ាប់រងផ្តល់កិច្ចធានាកាន់តែពេញលក្ខណៈដល់ប្រជាជន ។ នៅថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០១៩ វេបសាយសេវាកម្មប្រព័ន្ធធានារ៉ាប់រងបានត្រូវប្រកាសឱ្យប្រើប្រាស់ជាផ្លូវការ ។ គិតមកដល់ពេលនេះប្រជាជនចិនដែលកាន់ប័ណ្ណធានារ៉ាប់រងសង្គមកិច្ចមានចំនួនជាង១៣០០លាននាក់ ដែលបានគ្របដណ្តប់លើប្រជាជន៩៣ភាគរយ ។ រដ្ឋាភិបាលចិនបានផ្តល់ប័ណ្ណធានារ៉ាប់រងសង្គមកិច្ចអេឡិចត្រូនិកជាង៨០លានសន្លឹក ។ គិតមកដល់ចុងខែតុលា ឆ្នាំ២០១៩ក្នុងចំណោមប្រជាជនក្រីក្រដែលបានចុះបញ្ជីនៅប្រទេសចិនមាន ៥៩,៧៧លាននាក់បានចូលរួមក្នុងប្រព័ន្ធធានារ៉ាប់រងចាស់ជរា ។

សព្វថ្ងៃខេត្តចំនួន ២៣និង តំបន់ស៊ីនជាំងនៃប្រទេសចិនបានដាក់ចេញនូវគោលនយោបាយអំពីការកែសម្រួលស្តង់ដារធានារ៉ាប់រងចាស់ជរា ហើយមានខេត្តចំនួន១០បានលើកកម្ពស់កម្រិតនៃប្រាក់ឧបត្ថម្ភសម្រាប់មនុស្សចាស់ដែលចូលរួមប្រព័ន្ធធានារ៉ាប់រងចាស់ជរា ៕

**ដោយ លី ជីន(កាសែតប្រជាជនដេលី)**

## ឯកឧត្តម ស៊ីជីន ភីងបកស្រាយពី "ការកាន់អំណាចដោយប្រជាជនជាមូលដ្ឋានគ្រឹះសំខាន់ជាងគេ"

ប្រជាជនជាមូលដ្ឋានគ្រឹះយ៉ាងរឹងមាំនៃប្រទេសចិនចំណែកការកាន់អំណាចដោយប្រជាជនជាមូលដ្ឋានគ្រឹះសំខាន់ជាងគេ ។ ក្នុងដំណើរអភិវឌ្ឍន៍រយៈពេលកន្លងទៅប្រជាជនចិនខ្លួនទីពឹងខ្លួនខិតខំឧស្សាហ៍ព្យាយាមនិងបានបង្កើតជា"អច្ឆរិយៈចិន"ដែលទទួលការចាប់អារម្មណ៍ពីពិភពលោកទាំងមូល។ ក្នុងដំណើរអភិវឌ្ឍន៍ថ្មី ទោះបីជាមានឧបសគ្គអ្វីក៏ដោយ មានខ្យល់ខ្លាំងឬរលកធំប៉ុនណាក៏ដោយ យើងសុទ្ធតែត្រូវពឹងផ្អែកលើប្រជាជនប្រកាន់ខ្ជាប់នូវគោលការណ៍ខ្លួនទីពឹងខ្លួននិងខិតខំឧស្សាហ៍ព្យាយាមដើម្បីជំរុញឱ្យបុព្វហេតុដ៏មហិមាដែលមិនធ្លាប់មានពីមុនឈានទៅមុខជាជំហានៗ អាស្រ័យលើជំនឿចិត្តយ៉ាងរឹងមាំដូចថ្មរឹងស្មារតីមិនចេះនឿយហត់និងឆន្ទៈមោះមុតដែលមិនងាយរេ ៕

**(ដកស្រង់ចេញពីសុន្ទរកថាអបអរសាទរឆ្នាំសាកលថ្មី២០១៩ របស់ឯកឧត្តមស៊ី ជីនភីងដែលថ្លែងនៅថ្ងៃទី ៣១ ខែធ្នូឆ្នាំ ២០១៨)**

## ទំនិញឆ្លងបុណ្យចូលឆ្នាំថ្មីចិនទទួលការពេញនិយមតាមទីផ្សារ



ក្នុងឱកាសជិតចូលឆ្នាំថ្មីចិននេះ ទំនិញសម្រាប់ឆ្លងបុណ្យចូលឆ្នាំថ្មីចិនបានទទួលការពេញនិយមកាន់តែច្រើនតាមទីផ្សារក្នុងប្រទេសចិន ។ ពេលថ្មីៗនេះពិព័រណ៍ទំនិញឆ្លងបុណ្យចូលឆ្នាំថ្មីចិនក្រុងគុនមីងប្រទេសចិន លើកទី១៤ បានរៀបចំនៅមជ្ឈមណ្ឌលសន្និសីទនិងពិព័រណ៍ក្រុងគុនមីង ។ គ្រឿងបរិភោគ សម្ភារប្រើប្រាស់និងទំនិញដែលនាំចូលពីប្រទេសជាង២០នៃតំបន់អាស៊ីខាងត្បូងអាស៊ីអាគ្នេយ៍ អឺរ៉ុប អាមេរិកនិងអាហ្វ្រិកជាដើមបានត្រូវតាំងពិព័រណ៍ក្នុងពន្លាពិព័រណ៍ដែលមានទំហំជាង៥ ម៉ឺនម៉ែត្រការ៉េនោះ ។ ពិព័រណ៍នេះបានផ្តល់ផលិតផលច្រើនដល់អ្នកក្រុងហើយបានធ្វើឱ្យអ្នកក្រុងអាចទិញបានទំនិញឆ្លងបុណ្យចូលឆ្នាំថ្មីចិនដែលមានតម្លៃទាប និងគុណភាពខ្ពស់ព្រមទាំងបានធ្វើឱ្យអ្នកក្រុងមានចំណាប់អារម្មណ៍ចំពោះបរិយាកាសប្រកបដោយភាពសប្បាយរីករាយដើម្បីអបអរសាទរបុណ្យចូលឆ្នាំប្រពៃណីចិន ៕

**ដោយ យ៉ាងជីង**

## វត្ថុសិប្បកម្មស្ពាន់ និងប្រាក់កាន់តែមានកម្លាំងទាក់ទាញ



*ជាងសិប្បកម្មកំពុង បង្ហាញពីវិធីធ្វើវត្ថុសិប្បកម្មស្ពាន់ និងប្រាក់ខេត្តយូនណាន*

វត្ថុសិប្បកម្មស្ពាន់និងប្រាក់ជាវត្ថុសិប្បកម្មស្ពាន់ប្រពៃណីចិនដែលមានលក្ខណៈពិសេសខេត្តយូនណាន ។ វត្ថុសិប្បកម្មនេះធ្វើពីស្ពាន់ហើយមានរូបចម្លាក់នៅលើនិងចាក់លោហៈប្រាក់ដែលបានត្រូវរំលាយ ។ ចាំវាត្រជាក់សំលៀងឱ្យរលោងយូរៗទៅវាមានពណ៌ខ្មៅហើយមានរូបពណ៌ស និងពណ៌លឿងនៅលើផ្ទៃវាពិតជាស្អាតណាស់មើលទៅ ។

វត្ថុសិប្បកម្មប្រភេទនេះ មានប្រវត្តិសាស្ត្រជាង៣០០ឆ្នាំហើយ ។ កាលមុនគេយកវត្ថុសិប្បកម្មនេះ ធ្វើជាប្រដាប់ប្រើប្រាស់ក្នុងបន្ទប់សិក្សា។ សព្វថ្ងៃគេចូលចិត្តប្រើសិប្បកម្មនេះមកធ្វើប្រដាប់លេងវត្ថុតុបតែងផ្ទះវត្ថុតុបតែងខ្លួននិងប្រដាប់ប្រើប្រាស់ជាដើម ហើយបាននិងកំពុងទទួលការពេញនិយមកាន់តែច្រើនឡើងៗ ។ នៅឆ្នាំ២០១១ វត្ថុសិប្បកម្មស្ពាន់និងប្រាក់ខេត្តយូនណានបានត្រូវដាក់បញ្ចូលក្នុងបញ្ជីឈ្មោះបេតិកភណ្ឌវប្បធម៌អរូបីថ្នាក់ជាតិក្រុមទី៣ របស់ប្រទេសចិន ៕

(កាសែតយូនណានដេលី)

## កាត់បន្ថយភាពក្រីក្រដោយតម្រង់ទិសផ្លូវដើរទៅកាន់សុភមង្គល

នៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ ២០១៩ អ្នកភូមិរួមគ្នាពិគ្រោះពិភាក្សាអំពីការកាត់បន្ថយភាពក្រីក្រនៅទីធ្លាផ្ទះលោកតឹងស្យៀស៊ីងក្នុងក្រុមឈើកឺសាំងភូមិជូស្យៀងឃុំយ៉ុងឈុនស្រុកស្វយ័តជនជាតិលីស៊ូវីស៊ី ខេត្តយូនណាន ។ "កូនស្រីច្បងកំពុងរៀនសេដ្ឋកិច្ចនៅសាកលវិទ្យាល័យស៊ីឈួនកូនស្រីទី ២កំពុងរៀនមុខវិជ្ជាគុណភាពនិងសុវត្ថិភាពគ្រឿងបរិភោគនៅសាកលវិទ្យាល័យពេទ្យចិនសែខេត្តយូនណាន កូនស្រីពៅកំពុងរៀននៅអនុវិទ្យាល័យក្នុងក្រុងតាលី ។ យើងត្រូវជួយលោក តឹង ស្យៀស៊ីងឱ្យកូនស្រីទាំង៣របស់លោកបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ ។

ក្នុងភូមិជូស្យៀងនេះអ្នកភូមិគ្រប់គ្នាសុទ្ធតែយកចិត្តទុកដាក់ដល់ការអប់រំ ។ ទោះជាកូនប្រុសឬកូនស្រីឪពុកម្តាយសុទ្ធតែគាំទ្រឱ្យពួកគេទៅចូលរៀននៅសាលា ។ លោកចាវ ជាំងហុង លេខាបក្សគណៈរដ្ឋបាល ភូមិជូស្យៀងបានបញ្ជាក់ថា អនាគតមានភាពភ្លឺស្វាងតែមានការលំបាកច្រើនក្នុងការជូនកូនទៅរៀន ។

ប្រពន្ធរបស់លោកតឹង ស្យៀស៊ីង និយាយថាមានការយកចិត្តទុក ដាក់ពីបក្សនិងរដ្ឋាភិបាលរឿងនេះ មិនពិបាកទេ ។ សព្វថ្ងៃប្តីខ្ញុំធ្វើការជាអ្នកការពារសន្តិសុខនៅសាលាបឋមសិក្សាជនជាតិភាគតិចនៅទីរួមស្រុកហើយអាចទទួលបានប្រាក់ខែ១.៥០០យ៉ាន់ ។ ខ្ញុំធ្វើជាអ្នកបោសសម្អាតផ្លូវនិងអ្នកការពារព្រៃឈើអាចទទួលបានចំណូល៥០០យ៉ាន់និងជិត៨០០យ៉ាន់ជារៀងរាល់ខែ ។ ទាំងនេះសុទ្ធតែមកពីការ ជួយឧបត្ថម្ភពីអ្នកភូមិទាំងអស់គ្នា។ ខ្ញុំសូមថ្លែងអំណរគុណដល់បក្ស និងរដ្ឋាភិបាល ។

លោកតឹង ស្យៀស៊ីង បានបន្ថែមថា ក្រៅពីនេះខ្ញុំនៅបានទទួលការជួយឧបត្ថម្ភជាច្រើនទៀត ។ នៅពេលខ្ញុំសង់ផ្ទះថ្មីក្នុងឆ្នាំ២០១៧ ខ្ញុំបានទទួលប្រាក់ឧបត្ថម្ភ២ ម៉ឺនយ៉ាន់ ។ ខ្ញុំបានខ្ចីប្រាក់ឥណទានសម្រាប់ជូនកូនទៅរៀនមួយឆ្នាំបាន៨.០០០យ៉ាន់អាចយកទៅបង់ថ្លៃសិក្សាឱ្យកូន។ក្រោយពីបានអនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្រដោយតម្រង់ទិសរដ្ឋបាលមណ្ឌលស្វយ័តជនជាតិទីបេទីឈីងបានអនុវត្តគោលនយោបាយអំពីការផ្តល់ការអប់រំឥតគិតថ្លៃរយៈពេល១៤ឆ្នាំ ។ នេះមានន័យថា មុននឹងចូលរៀននៅសាកលវិទ្យាល័យឪពុកម្តាយមិនបាច់បង់ថ្លៃសិក្សាឱ្យកូនទេ ។



*និយាយអំពីការរស់នៅសព្វថ្ងៃ ប្រពន្ធលោកតឹង ស្យៀស៊ីងបញ្ចេញស្នាមញញឹមភ្លាមៗ*

លោកចាវ ជាំងហុង បន្តទៀតថា ខ្ញុំមកធ្វើការនៅភូមិជូស្យៀងតាំងពីឆ្នាំ២០១៥ ហើយជាអ្នកចូលរួមផ្ទាល់និងជាអ្នកសាក្សីនៃការអនុវត្តន៍គោលនយោបាយកាត់បន្ថយភាពក្រីក្រដោយតម្រង់ទិស ។ គោលនយោបាយនេះមិនគ្រាន់តែបាននាំមកនូវជីវភាពសុភមង្គលដល់គ្រួសាររបស់លោកតឹងស្យៀស៊ីងប៉ុណ្ណោះទេ ថែមទាំងបានធ្វើឱ្យភូមិជូស្យៀងមានការផ្លាស់ប្តូរច្រើនគួរឱ្យកត់សម្គាល់ទៀតផង ។ អ្នកភូមិគ្រប់គ្នាសុទ្ធតែបានទទួលនូវផលប្រយោជន៍ជាក់ស្តែង ៕

**ដោយ ឈូ តុងហួ ស្យូង យ៉ាន លី ហ៊ឹងឈាំងនិង លី វិនជួន**